# សួស្តី មកពី ប្រទេស ហ្វីលីពីន !






មានប្រជាជនប្រហែលជាមួយរយលាននាក់រស់នៅប្រទេសហ្វីលីពីន ដែលមានសត្វដ៏គួរឲ្យចាប់អារម្មណ៍ជាច្រើន !








មានភាសាធំៗចំនួនប្រាំបីត្រូវបាននិយាយនៅប្រទេសហ្វីលីពីន ។ ព្រះគម្ពីរមរមនត្រូវបានបោះពុម្ពជាភាសាមួយហៅថាសេប៊ូអាណូ ។



តើអ្នកទៅព្រះវិហារដោយរបៀបណា ? នៅប្រទេសហ្វីលីពីនគ្រួសារមួយចំនួនជិះឡានម៉ាកស៊ីបវែងជាយានជំនិះ !

រូបថតឡានស៊ីបវែងមកពី GETTY IMAGES; រចនារូបភាពដោយ ដាវី ម៉ាក់ឌី




នេះជាចិញ្ចៀន ជ.ផ.ត. ជាភាសាមួយរបស់ហ្វីលីពីនហៅថាតាកាឡុក ។ នេះជារបៀបនិយាយថា « ជ្រើសផ្លូវត្រូវ » ៖ *piliin ang tama* ។





នេះគឺជាព្រះវិហារបរិសុទ្ធនៅទីក្រុងសេប៊ូ និងម៉ានីល ។ ហើយសូមមើលមានអ្វីទៀត ? ព្រះវិហារបរិសុទ្ធទីពីរកំពុងសាងសង់នៅទីក្រុងម៉ានីល ! ហើយព្រះវិហារបរិសុទ្ធក៏កំពុងត្រូវបានសាងសង់នៅក្នុងទីក្រុងពីរបន្ថែមទៀតគឺទីក្រុងអ៊ូដានេតា និងកាយ៉ាយ៉ាន ឌឺ អូរ៉ូ ។



កុមារហ្វីលីពីនលេងល្បែងកម្សាន្តមួយហៅថា *luksong tinik* ឬ « ការលោតរំលងបន្លា » ។ កុមារម្នាក់ ឬពីរនាក់អង្គុយលើកម្រាលឥដ្ឋ ហើយដាក់ជើង និងដៃរបស់ពួកគេគរលើគ្នា ។ បន្ទាប់មកកុមារផ្សេងទៀតព្យាយាមលោតរំលងលើវាដោយពុំឲ្យប៉ះដៃ ឬជើងនោះឡើយ ។

## សូមជួបជាមួយមិត្តភក្តិមួយចំនួនរបស់យើងមកពីប្រទេសហ្វីលីពីន !




« ខ្ញុំទន្ទឹងចាំការអានព្រះគម្ពីររបស់យើងជាគ្រួសារនៅពេលល្ងាច ។ ខ្ញុំមានអារម្មណ៍ល្អជានិច្ច ពេលខ្ញុំអានព្រះគម្ពីរ » ។

**ឡានទៀ ឌី អាយុ ១០ ឆ្នាំ ទីក្រុងសេនត្រុល លូស្សូន ប្រទេសហ្វីលីពីន**




« នៅគ្រាដំបូងដែលខ្ញុំរៀនអានអក្សរ ខ្ញុំមានអារម្មណ៍កើតទុក្ខ ដោយសារខ្ញុំពុំអាចអានបានលឿនឡើយ ។ ឪពុកម្ដាយ និងបងស្រីខ្ញុំបានជួយខ្ញុំ ហើយឥឡូវនេះ ខ្ញុំរំភើបចិត្តនឹងអានព្រះគម្ពីរណាស់ » ។

**អាគូមែន អាយុ ៧ ឆ្នាំ ទីក្រុង សេនត្រុល លូស្សូន ប្រទេសហ្វីលីពីន**

តើប្អូនមកពីប្រទេសហ្វីលីពីនឬ ? សូមសរសេរមកកាន់ពួកយើង ! ពួកយើងចង់ឮពីប្អូនៗ ។

